**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation
លេខ: ០០៧ MISTI / ២០២១

# សេចក្តីណែនាំបន្ថែម
## ស្តីពី
## វិធានការបន្ទាន់ដើម្បីចូលរួមបង្ការ និងទប់ស្កាត់ការរាតត្បាតជំងឺកូវីដ-១៩ ក្នុងសហគមន៍ ពាក់ព័ន្ធនឹង «ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ»

យោងតាមបទបញ្ជា និងប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នាថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ និងផ្អែកតាមការណែនាំយ៉ាងមឲ្យតពី **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី** នាកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការចូលរួមបង្ការ និងទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ ក្នុងសហគមន៍ នៅកម្ពុជា និងដើម្បីអនុវត្តឱ្យស្របតាមវិធានការណែនាំ របស់ក្រសួងសុខាភិបាល ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សូមធ្វើការណែនាំបន្ថែមដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ និងគ្រប់អង្គភាពចំណុះក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមទាំងបណ្តាមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍រាជធានី ខេត្ត ទាំងអស់ ដូចខាងក្រោម៖

១. គ្រប់អង្គភាពទាំងអស់ត្រូវរៀបចំវេនប្រចាំការការងារ ដោយកម្រិតចំនួនជាអតិបរមាក្នុងរង្វង់ ២នាក់ទៅ៣នាក់ ដែលក្នុងនោះ ចាំបាច់មានថ្នាក់ជំនាញ ១រូប ថ្នាក់នាយកដ្ឋាន ១រូប និងថ្នាក់អគ្គនាយកដ្ឋាន ១រូប ។ ចំពោះមន្ត្រីដែលមិនស្ថិតនៅក្នុងវេន ត្រូវមកប្រចាំការការងារនៅក្រសួង ឬអង្គភាព ត្រូវធ្វើការស្នាក់នៅក្នុងផ្ទះ ហើយបំពេញការងារជាធម្មតាតាមប្រព័ន្ធអនឡាញ (Online) ក្នុងដំណាក់កាលនៃការអនុវត្តវិធានការបង្ការ និងទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ ក្នុងសហគមន៍ដែលកំពុងតែស្ថិតក្នុងកម្រិតប្រុងប្រយ័ត្នខ្ពស់។

២. រាល់កិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល ឬការជួបជុំទាំងឡាយ ត្រូវកំណត់ឱ្យផ្អាកទាំងស្រុង រយៈពេលយ៉ាងតិច ២សប្តាហ៍ ចាប់ពីថ្ងៃចេញសេចក្តីណែនាំបន្ថែមនេះតទៅ។ អង្គភាពនីមួយៗអាចរៀបចំកិច្ចប្រជុំពិភាក្សារបស់ខ្លួនក្នុងករណីចាំបាច់តាមប្រព័ន្ធអនឡាញ ដោយប្រើប្រាស់កុំព្យូទ័រផ្ទាល់ខ្លួនជាលក្ខណៈបុគ្គល និងស្ថិតនៅទីទៃ។

៣. ថ្នាក់ដឹកនាំ មន្ត្រីរាជការទាំងអស់ ត្រូវចូលរួមស្កេន QR Code «ទប់ស្កាត់កូវីដ-១៩ (Stop Covid-19)» ដែលមាននៅតាមច្រកចេញ-ចូល នៃទីស្តីការក្រសួង ឬអង្គភាព ជារៀងរាល់ពេលមកបំពេញការងារនៅទីស្តីការក្រសួង ឬអង្គភាព ដើម្បីបង្ការសុខភាព និងចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺរាតត្បាតជាសកលនេះ។

៤. ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់នូវវិធានការ « ៣ ការពារ និង ៣ កុំ » តាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា៖**



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៣៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

- ៣ ការពារ៖
  - ពាក់ម៉ាស់
  - លាងដៃ (នឹងសាប៊ូអាល់កុលកែហ្សេល ឬសារធាតុសម្លាប់មេរោគផ្សេងៗ)
  - រក្សាគម្លាតសុវត្ថិភាពសង្គម និងគម្លាតសុវត្ថិភាពបុគ្គល (ចាប់ពី ១ម៉ែត្រកន្លះឡើងទៅ ឱ្យបានគ្រប់ៗគ្នា នៅគ្រប់ទីកន្លែងទាំងអស់។
- ៣ កុំ៖
  - កុំចូលទៅកន្លែងបិទជិត គ្មានខ្យល់ចេញ-ចូល និងប្រើប្រាស់ម៉ាស៊ីនត្រជាក់ច្រើនពេក ត្រូវរកកន្លែងដែលមានខ្យល់ចេញ-ចូលគ្រប់គ្រាន់
  - កុំទៅកន្លែងដែលមានមនុស្សច្រើនកុះករ
  - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា កុំកៀកស្មាគ្នា កុំឱបគ្នា ជាដើម។

៥. គ្រប់អង្គភាពទាំងអស់ក្រោមឱវាទក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមទាំងមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានី ខេត្ត ត្រូវធ្វើការតាមដាន និងរាយការណ៍ជាប្រចាំអំពីស្ថានភាពសុខភាពរបស់មន្ត្រីក្រោមឱវាទ។ ក្នុងករណីមន្ត្រីណាមួយមានការសង្ស័យ ដោយមានរោគសញ្ញាស្រដៀងនឹងជំងឺកូវីដ-១៩ ត្រូវទូរស័ព្ទជាបន្ទាន់ទៅលេខ១១៥ និងរាយការណ៍មកក្រសួងតាមរយៈអគ្គនាយកដ្ឋានកិច្ចការទូទៅ។

៦. ចំពោះថ្នាក់ដឹកនាំ ឬមន្ត្រីដែលស្នាក់នៅក្នុងតំបន់ ឬទីកន្លែងណាមួយស្ថិតនៅក្នុងបញ្ជីទីតាំងពាក់ព័ន្ធព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១ ឬបានប្រាស្រ័យជាមួយអ្នកដែលសង្ស័យថាមានការពាក់ព័ន្ធនឹងព្រឹត្តិការណ៍សហគមន៍២០ កុម្ភៈ ត្រូវប្រញាប់ប្រញាល់រាយការណ៍មកក្រសួង ឬផ្តល់សំណាកទៅក្រសួងសុខាភិបាល ដើម្បីធ្វើតេស្ត ឬធ្វើស្វ័យចត្តាឡីស័កឱ្យបានប្រាកដប្រជា។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ និងគ្រប់អង្គភាពចំណុះក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមទាំងបណ្តាមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍រាជធានី ខេត្ត ទាំងអស់ ត្រូវចូលរួមសហការអនុវត្តនូវវិធានការនេះឱ្យបានម៉ឺងម៉ាត់ និងធ្វើការផ្សព្វផ្សាយនូវសេចក្តីណែនាំបន្ថែមនេះ ឱ្យបានទូលំទូលាយ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

សូមតាមដានជាប្រចាំនូវការផ្សព្វផ្សាយអំពីបទបញ្ជា និងសេចក្តីណែនាំបន្ថែមរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងសុខាភិបាល ក៏ដូចជាការណែនាំថ្មីៗរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ថ្ងៃ ព្រហស្បតិ៍ ១៤ កើត ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០២១

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៨ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១០ ៧៨៥
អ៊ីម៉ែល: misti.smcabinet@gmail.com